អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០១៨

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**OFFICE OF THE CO-INVESTIGATING JUDGES**
**BUREAU DES CO-JUGES D'INSTRUCTION**

# សេចក្តីប្រកាសព័ត៌មាន

## សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញលើដីកាដំណោះស្រាយ ហើយដាក់សំណៅសាធារណៈដែលមានការកោសលុបនៃដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង អោ អាន

## សំណុំរឿង លេខ ០០៤/០២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

នៅថ្ងៃនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់សំណៅសាធារណៈដែលមានការកោសលុបនៃដីកាដំណោះស្រាយ និងឧបសម្ព័ន្ធ III នៅក្នុងសំណុំរឿង ០០៤/២ ហើយបានចេញដីកាសម្រេចថា ដីកាដំណោះស្រាយ និងឧបសម្ព័ន្ធ III ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨ ត្រូវធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញទៅជាឯកសារសម្ងាត់ ពីព្រោះថាមានការលើកឡើងដោយចៃដន្យនូវឈ្មោះពេញលេញរបស់សាក្សីពីរនាក់ដែលត្រូវការពារ។

ការផ្សព្វផ្សាយណាមួយអំពីសំណៅគ្មានការកោសលុបនៃដីកាដំណោះស្រាយ និងឧបសម្ព័ន្ធ III របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងសំណុំរឿង ០០៤/២ ឬការផ្សព្វផ្សាយណាមួយអំពីឈ្មោះរបស់សាក្សីទាំងពីរនាក់ដែលត្រូវការពារ អាចត្រូវដាក់ទោសដោយ អ.វ.ត.ក ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច យោងតាមវិធានផ្ទៃក្នុង ២៩(៥) និង ៣៥(១)(ក)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងឧបសម្ព័ន្ធ III ដែលការកោសលុប អាចរកបាននៅលើគេហទំព័ររបស់ អ.វ.ត.ក

https://eccc.gov.kh/en/document/court/redacted-closing-order-indictment
https://eccc.gov.kh/en/document/court/redacted-annex-iii-witnesses-forced-marriage-province


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**

ប្រធានផ្នែកកិច្ចការសាធារណៈ និងមន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម

ទូរសព្ទដៃ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦

អ៊ីមែល៖ neth.pheaktra@eccc.gov.kh



www.eccc.gov.kh